ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៣៦៤៣.ណ.ទ.ស.២៥

ក្រសួងមហាផ្ទៃ

សេចក្តីណែនាំអន្តរក្រសួង
ស្តីពី
ការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យពាណិជ្ជកម្ម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវារដ្ឋបាលក្នុងវិស័យពាណិជ្ជកម្ម ស្របតាមស្មារតីនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ ១៨២ ១៨៣ និង១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក និងខណ្ឌនៃរដ្ឋបាលរាជធានីភ្នំពេញ អនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ និងអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម មុខងារផ្តល់សេវារដ្ឋបាលចំនួនពីរក្នុងវិស័យពាណិជ្ជកម្ម ត្រូវបានប្រគល់ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន៖

១- ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម។

២- ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ។

ដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យពាណិជ្ជកម្មនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រសួងពាណិជ្ជកម្ម និងក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

I- ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម

១- គោលការណ៍

រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចគ្រប់គ្រងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មតាមគោលការណ៍ដូចខាងក្រោម៖

- លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្ម ត្រូវផ្តល់ជូន៖
  - អាជីវករ សេវាករ ពាណិជ្ជករដែលមានសញ្ជាតិខ្មែរ និងមានបំណងធ្វើអាជីវកម្ម ឬកំពុងធ្វើសកម្មភាពទិញ លក់ ឬធ្វើសេវាកម្មជាប្រចាំក្នុងគោលដៅស្វែងរកប្រាក់ចំណេញ
  - អាជីវកម្មដែលមានទីតាំងប្រកបមុខរបរច្បាស់លាស់ស្របតាមច្បាប់កំណត់ និងមិនស្ថិតនៅក្នុងការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដូចមានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ contact@moc.gov.kh

- ចំពោះអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្មដែលមានម្ចាស់ជាសញ្ជាតិបរទេស ឬប្រជាពលរដ្ឋខ្មែរដែលស្ថិតនៅក្នុងការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមានកាតព្វកិច្ចចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម
- ក្រោយពីបានទទួលលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មរួចហើយ អាជីវករ សេវាករ និងពាណិជ្ជករទាំងអស់ត្រូវ៖
  - ប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មនៅទីតាំងដែលបានកំណត់ក្នុងលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្ម
  - បិទស្លាកថ្លៃជាប្រាក់រៀលលើគ្រប់មុខទំនិញនិងសេវារបស់ខ្លួននីមួយៗឱ្យបានច្បាស់លាស់ និងគោរពតាមបញ្ញត្តិផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម
  - ស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមវិស័យជំនាញផ្សេងៗទៅតាមប្រភេទអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម។
- ករណីមានការផ្លាស់ប្តូរទីតាំងអាជីវកម្ម ឬផ្លាស់ប្តូរម្ចាស់អាជីវកម្ម អាជីវករ សេវាករ ពាណិជ្ជករ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម សាជាថ្មីនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលទីតាំងអាជីវកម្មនោះស្ថិតនៅ
- ករណីផ្អាក និងបិទអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ម្ចាស់អាជីវកម្ម ត្រូវជូនដំណឹងមករដ្ឋបាលក្រុង ស្រុក ខណ្ឌដែលទីតាំងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មស្ថិតនៅឱ្យបានមុនរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ
- អាជីវករ សេវាករ ពាណិជ្ជករ ត្រូវតែដាក់ពាក្យស្នើសុំបន្តលិខិតអនុញ្ញាតឱ្យបានមុនរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ មុនពេលលិខិតអនុញ្ញាតផុតសុពលភាព។ នីតិវិធី និងកម្រៃសេវានៃការស្នើសុំបន្តលិខិតអនុញ្ញាតនេះ ត្រូវអនុវត្តដូចការស្នើសុំលិខិតអនុញ្ញាតលើកដំបូង
- ការប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មដោយមិនមានលិខិតអនុញ្ញាត ត្រូវចាត់ទុកជាការប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម មិនស្របច្បាប់។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការណាមួយអាស្រ័យទៅតាមស្ថានភាព និងភាពចាំបាច់លើការគ្រប់គ្រងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចខាងក្រោម៖
  - ក- ចេញលិខិតអញ្ជើញ
  - ខ- ធ្វើលិខិតព្រមានជាលាយលក្ខណ៍អក្សរ
  - គ- ផ្អាកសកម្មភាពអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មជាបណ្តោះអាសន្ន (រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងមូលដ្ឋានរបស់ខ្លួន)។

២- ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ប្រជាពលរដ្ឋដែលមានបំណងស្នើសុំលិខិតអនុញ្ញាត ឬបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

ក. ការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម

- ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ..... ចំនួន ១ច្បាប់
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬ មានផ្តិតមេដៃទទួលស្គាល់ពីសាមីខ្លួន) ..... ចំនួន ១ច្បាប់
- គំរូវិក្កយបត្រសម្រាប់ការប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មរបស់ខ្លួន ..... ចំនួន ១ច្បាប់
- រូបថតម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦ .....ចំនួន ៣សន្លឹក
- កិច្ចសន្យា ..... ចំនួន ១ច្បាប់
- គំនូសបង្ហាញទីតាំងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម .....ចំនួន ១ច្បាប់។

ខ. ការស្នើសុំបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម

- ពាក្យស្នើសុំបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម..... ចំនួន ១ច្បាប់
- រូបថតម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦ .....ចំនួន ៣សន្លឹក
- កិច្ចសន្យា ..... ចំនួន ១ច្បាប់
- លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ដែលជិតផុតសុពលភាព(ច្បាប់ថតចម្លង).... ..... ចំនួន ១ច្បាប់។

៣. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ ប្រជាពលរដ្ឋត្រូវមកដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលទីតាំងប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ពីប្រធានការិយាល័យច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយ ត្រូវពិនិត្យពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ និងពិគ្រោះយោបល់ជាមួយប្រធានការិយាល័យច្រកចេញចូលតែមួយ ដើម្បីកំណត់កាលបរិច្ឆេទចុះអង្កេតវាយតម្លៃទីតាំងស្នើសុំប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម
- បុគ្គលិកផ្នែកជួរក្រោយ ត្រូវពិនិត្យវាយតម្លៃ និងរៀបចំរបាយការណ៍ចុះអង្កេតវាយតម្លៃទីតាំងស្នើសុំប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ដោយផ្អែកលើចំណុចសំខាន់ៗដូចខាងក្រោម៖
  - ទីតាំងអាជីវកម្ម ៖ ពិនិត្យស្ថានភាព ជាទីតាំងបើកអាជីវកម្មពិតប្រាកដដែរឬទេ?
  - អ្នកស្នើសុំសេវា ៖ ពិនិត្យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬជាជនបរទេស?
  - ប្រភេទអាជីវកម្ម៖ ពិនិត្យលើកម្មវត្ថុអាជីវកម្ម មិនត្រូវខុសពីការលើកផ្លាកសញ្ញា
  - ទំហំអាជីវកម្ម ៖ ពិនិត្យស្ថានភាពនៃទំហំទីតាំងអាជីវកម្មជាក់ស្តែង។

- បន្ទាប់ពីបានចុះអង្កេតវាយតម្លៃទីតាំងរួច បុគ្គលិកផ្នែកជួរក្រោយត្រូវ៖
  - <u>ករណីការស្នើសុំមានលក្ខណៈសមស្របតាមបទដ្ឋានបច្ចេកទេស</u>៖ រៀបចំកំណត់បង្ហាញរឿងដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ និងសេចក្តីព្រាងលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ។
  - <u>ករណីការស្នើសុំមិនមានលក្ខណៈសមស្របតាមបទដ្ឋានបច្ចេកទេស</u>៖ រៀបចំកំណត់បង្ហាញរឿងដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ និងសេចក្តីព្រាងលិខិតឆ្លើយតបដោយបញ្ជាក់អំពីមូលហេតុដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនអាចផ្តល់លិខិតអនុញ្ញាតជូនទៅអ្នកស្នើសុំសេវា រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ។
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីបុគ្គលិកផ្នែកជួរក្រោយ ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតឆ្លើយតបដាក់ជូនទៅអភិបាល ឬអ្នកមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

II- ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ

១. គោលការណ៍

រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចគ្រប់គ្រងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ។ ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ សំដៅដល់លោហធាតុ (មាស ប្រាក់ ផ្លាកទីន) និងត្បូងថ្មមានតម្លៃដែលបានកែច្នៃរួច (លើកលែងផលិតផលគ្រឿងកាឡៃ) ហើយកំពុងធ្វើចរាចរនៅលើទីផ្សារ
- រូបវន្តបុគ្គលដែលមានបំណងប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ហើយមិនស្ថិតក្នុងការធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទក្នុងពេលតែមួយតែម្តងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងអាជីវកម្មស្ថិតនៅ
- ចំពោះរូបវន្តបុគ្គលដែលស្ថិតក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ឬនីតិបុគ្គលដែលមានបំណងប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មជាមុនសិនទើបទៅដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងអាជីវកម្មស្ថិតនៅ

- ក្រោយពីបានទទួលលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទរួចហើយ អាជីវករត្រូវ៖
  - ប្រកបមុខរបររបស់ខ្លួន នៅតាមទីតាំងដែលបានកំណត់ក្នុងលិខិតអនុញ្ញាត
  - បិទស្លាកថ្លៃជាប្រាក់រៀលលើគ្រឿងអលង្ការគ្រប់ប្រភេទនីមួយៗឱ្យបានច្បាស់លាស់ និង
  - ចេញវិក្កយបត្រតាមទម្រង់ដែលមានការទទួលស្គាល់ផ្លូវការពីស្ថាប័នមានសមត្ថកិច្ច (ករណីនីតិបុគ្គល មានគំរូស្រាប់តាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀត) និងមានលិខិតធានាអំពីគុណភាពតាមការបញ្ជាក់អះអាងរបស់ខ្លួនជូនអតិថិជនគ្រប់ការទិញលក់។ លិខិតធានាគុណភាព ត្រូវមានបញ្ជាក់អំពីឈ្មោះក្រុមហ៊ុន សហគ្រាស ឬឈ្មោះអាជីវកម្មអាសយដ្ឋាន អាជីវកម្ម លេខទូរសព្ទដែលអាចទំនាក់ទំនងបាន ដោយបញ្ជាក់ពីប្រភពផលិតផលជានាភាពពិតប្រាកដនៃជាតុផ្សំ និងរូបភាពនៃផលិតផលទំនិញ ដើម្បីជៀសវាងអ្នកប្រើប្រាស់មានការភ័ន្តច្រឡំ ឬប៉ះពាល់ដល់ការប្រកួតប្រជែងស្មោះត្រង់។
- ករណីអាជីវករ សេវាករ ពាណិជ្ជករដែលមិនគោរពតាមខ្លឹមសារនៃសេចក្តីណែនាំនេះ និងសេចក្តីណែនាំផ្សេងៗទៀតរបស់ក្រសួងពាណិជ្ជកម្ម លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទនេះនឹងត្រូវដកហូតមុនកាលកំណត់នៃសុពលភាព
- ករណីមានការផ្លាស់ប្តូរទីតាំងអាជីវកម្ម ឬផ្លាស់ប្តូរម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម អាជីវករ សេវាករ ពាណិជ្ជករ ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទសាជាថ្មីនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងអាជីវកម្មនោះស្ថិតនៅ
- ករណីផ្អាក និងបិទអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម ម្ចាស់អាជីវកម្ម ត្រូវជូនដំណឹងមករដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មស្ថិតនៅឱ្យបានមុនរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ
- អាជីវករ សេវាករ ពាណិជ្ជករ ត្រូវតែដាក់ពាក្យស្នើសុំបន្តលិខិតអនុញ្ញាតឱ្យបានមុនរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការមុនលិខិតអនុញ្ញាតផុតសុពលភាព។ នីតិវិធី និងកម្រៃសេវានៃការស្នើសុំបន្តលិខិតអនុញ្ញាតនេះត្រូវអនុវត្តដូចការស្នើសុំលិខិតអនុញ្ញាតលើកដំបូង
- ការប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ដោយមិនមានលិខិតអនុញ្ញាត ត្រូវចាត់ទុកថាជាការប្រកបអាជីវកម្មមិនស្របច្បាប់។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការណាមួយ អាស្រ័យទៅតាមស្ថានភាព និងភាពចាំបាច់លើការគ្រប់គ្រងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចខាងក្រោម៖
  - ក- ចេញលិខិតអញ្ជើញ
  - ខ- ធ្វើលិខិតព្រមានជាលាយលក្ខណ៍អក្សរ
  - គ- ផ្អាកសកម្មភាពអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មជាបណ្តោះអាសន្ន (រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងមូលដ្ឋានរបស់ខ្លួន)។

២. ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាត ឬបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

ក.ការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ

- ពាក្យសុំអនុញ្ញាតប្រកបអាជីវកម្ម ..... ចំនួន ១ច្បាប់
- រូបវន្តបុគ្គល៖ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬមានផ្តិតមេដៃទទួលស្គាល់ពីសាមីខ្លួន) .... ចំនួន ១ច្បាប់
- នីតិបុគ្គល ៖ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ..... ចំនួន ១ច្បាប់
- គំរូវិក្កយបត្រអាជីវកម្មរបស់ខ្លួន (ច្បាប់ថតចម្លង) ..... ចំនួន ១ច្បាប់
- រូបថតម្ចាស់អាជីវកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦ ..... ចំនួន ៣សន្លឹក
- កិច្ចសន្យា ..... ចំនួន ១ច្បាប់
- គំនូសបង្ហាញទីតាំងអាជីវកម្ម ..... ចំនួន ១ច្បាប់។

ខ.ការស្នើសុំបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ

- ពាក្យស្នើសុំបន្តការអនុញ្ញាតប្រកបអាជីវកម្ម ..... ចំនួន ១ច្បាប់
- រូបថតម្ចាស់អាជីវកម្ម ពាណិជ្ជកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦ ..... ចំនួន ៣សន្លឹក
- កិច្ចសន្យា ..... ចំនួន ១ច្បាប់
- លិខិតអនុញ្ញាតប្រកបអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទដែលជិតផុតសុពលភាព (ច្បាប់ថតចម្លង) ..... ចំនួន ១ច្បាប់។

៣. នីតិវិធីនៃការផ្តល់សេវា

បន្ទាប់ពីបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់បានត្រឹមត្រូវ និងគ្រប់គ្រាន់ រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវមកដាក់ពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងអាជីវកម្មស្ថិតនៅ។ ដំណើរការនៃការផ្តល់សេវា ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ពីប្រធានការិយាល័យច្រកចេញចូលតែមួយ បុគ្គលិកផ្នែកជួរក្រោយ ត្រូវពិនិត្យពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ និងពិគ្រោះយោបល់ជាមួយប្រធានការិយាល័យច្រកចេញចូលតែមួយ ដើម្បីកំណត់កាលបរិច្ឆេទចុះអង្កេតវាយតម្លៃទីតាំងស្នើសុំប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ
- បុគ្គលិកផ្នែកជួរក្រោយ ត្រូវពិនិត្យវាយតម្លៃ និងរៀបចំរបាយការណ៍ចុះអង្កេតវាយតម្លៃទីតាំងស្នើសុំប្រកបអាជីវកម្ម ដោយផ្អែកលើចំណុចសំខាន់ៗដូចខាងក្រោម៖

- ទីតាំងអាជីវកម្ម ៖ ពិនិត្យស្ថានភាព ជាទីតាំងបើកអាជីវកម្មពិតប្រាកដដែរឬទេ ?
- អ្នកស្នើសុំសេវា ៖ ពិនិត្យអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនដែលមានសុពលភាព
- ប្រភេទអាជីវកម្ម៖ ពិនិត្យលើកម្មវត្ថុអាជីវកម្ម មិនត្រូវខុសពីការលើកផ្លាកសញ្ញា
- ទំហំអាជីវកម្ម ៖ ពិនិត្យស្ថានភាពនៃទំហំទីតាំងអាជីវកម្មជាក់ស្តែង។

- បន្ទាប់ពីបានចុះអង្កេតវាយតម្លៃទីតាំងរួច បុគ្គលិកផ្នែកជួរក្រោយត្រូវ៖
  - <u>ករណីការស្នើសុំមានលក្ខណៈសមស្របតាមបទដ្ឋានបច្ចេកទេស</u>៖ រៀបចំកំណត់បង្ហាញរឿងដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ និងសេចក្តីព្រាងលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ។
  - <u>ករណីការស្នើសុំមិនមានលក្ខណៈសមស្របតាមបទដ្ឋានបច្ចេកទេស</u>៖ រៀបចំកំណត់បង្ហាញរឿងដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ និងសេចក្តីព្រាងលិខិតឆ្លើយតបដោយបញ្ជាក់អំពីមូលហេតុនៃការមិនអាចផ្តល់សេវាជូនទៅអ្នកស្នើសុំសេវា រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយ។
- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីបុគ្គលិកផ្នែកជួរក្រោយ ប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវារដ្ឋបាល និងសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតឆ្លើយតបជាក់ជូនទៅអភិបាល ឬអ្នកមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

III. **កម្រៃសេវា រយៈពេលផ្តល់សេវា និងសុពលភាពនៃសេវា៖**

កម្រៃសេវា រយៈពេលផ្តល់សេវា និងសុពលភាពនៃសេវាសម្រាប់ការស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។

IV. **ការគ្រប់គ្រង ការតាមដាន និងការត្រួតពិនិត្យ៖**

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំឱ្យមានសម្រង់ព័ត៌មានអំពីទីតាំងប្រកបអាជីវកម្មដែលមានទីតាំងនៅក្នុងមូលដ្ឋានរបស់ខ្លួន និងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងយូរ ០៦ខែម្តង។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចាត់ចែងឱ្យមានការចុះត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើកិច្ចដំណើរការប្រកបអាជីវកម្មនៅទីតាំងអាជីវកម្មនីមួយៗ។

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវសហការជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ធ្វើការផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ ផ្តល់ការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ចំពោះការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យពាណិជ្ជកម្ម ដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

V. របាយការណ៍៖

រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ រួចផ្ញើមកមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីបូកសរុប និងរាយការណ៍ជូនក្រសួងពាណិជ្ជកម្ម។ របាយការណ៍របស់ក្រុង ស្រុក ខណ្ឌ ត្រូវចម្លងជូនក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី ខេត្តសាមី។

ទទួលបានសេចក្តីណែនាំអន្តរក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះឱ្យបានទូលំទូលាយ និងត្រូវទទួលបន្ទុកអនុវត្តឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣រោច ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ២០២៦

រដ្ឋមន្ត្រី	**ឧបនាយករដ្ឋមន្ត្រី**
ក្រសួងពាណិជ្ជកម្ម	**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
ចម នីម្មល	**អភិសន្តិបណ្ឌិត ស សុខា**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត៤*៦

ពាក្យស្នើសុំ
លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....(អក្សរឡាតាំង).....ភេទ.....
ថ្ងៃ-ខែ-ឆ្នាំកំណើត.....សញ្ជាតិ.....អាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....
ក្រុម.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....
ទូរសព្ទលេខ.....។

សូមគោរពជូន
លោក/លោកស្រីអភិបាល.....

កម្មវត្ថុ៖ សំណើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន លោក/លោកស្រីអភិបាល មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម៖.....
មានអាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....ក្រុម.....ភូមិ.....ឃុំ/សង្កាត់.....
ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....
ដោយមានឈ្មោះអាជីវកម្ម.....(ជាអក្សរឡាតាំង).....។

សូមជូនភ្ជាប់ជាមួយនូវ៖

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬមានផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន).....ចំនួន ០១ច្បាប់
២- គំរូវិក្កយបត្រសម្រាប់ការប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្មរបស់ខ្លួន.....ចំនួន ០១សន្លឹក
៣- រូបថតម្ចាស់អាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦ .....ចំនួន ០៣សន្លឹក
៤- កិច្ចសន្យា.....ចំនួន ០១ច្បាប់
៥- គំនូសបង្ហាញទីតាំងអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម .....ចំនួន០១ច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី **អភិបាល** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ៖..... (ជាអក្សរឡាតាំង) .....ភេទ.....
ថ្ងៃ-ខែ-ឆ្នាំកំណើត ៖.....សញ្ជាតិ.....
ទីកន្លែងកំណើត ៖.....
អាសយដ្ឋានបច្ចុប្បន្ន ៖.....
ឈ្មោះអាជីវកម្ម ៖.....
ទូរសព្ទលេខ ៖.....

សូមសន្យាថា៖

១- មានលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម មុននឹងចាប់ផ្តើមប្រកបអាជីវកម្ម
២- រាល់ការលក់ ត្រូវមានវិក្កយបត្រត្រឹមត្រូវ
៣- មិនក្លែងបន្លំគុណភាព រំលោភសេចក្តីទុកចិត្តអតិថិជន
៤- បិទស្លាកថ្លៃជាប្រាក់រៀលលើគ្រប់មុខទំនិញ និងសេវាដែលតាំងលក់
៥- ជូនដំណឹងមករដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានមុន៣០ថ្ងៃ ករណីឈប់ដំណើរការអាជីវកម្មមុនកាលកំណត់
៦- គោរពអនុវត្តតាមគោលការណ៍ច្បាប់ បទបញ្ជា ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗដោយធានាមិនធ្វើអ្វីឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ វប្បធម៌ និងប្រពៃណីជាតិ
៧- សហការផ្តល់ព័ត៌មានអំពីស្ថានភាពអាជីវកម្មជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ/មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត។

ក្នុងករណីខ្ញុំបាទ/នាងខ្ញុំមិនបានគោរព និងអនុវត្តតាមខ្លឹមសារដែលបានសន្យាខាងលើទេនោះ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំនូសបង្ហាញទីតាំង
ប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម

របស់ឈ្មោះ .....ឈ្មោះអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម.....
អាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ .....ផ្លូវ .....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ
.....រាជធានី/ខេត្ត .....ដូចបានបង្ហាញនៅក្នុងគំនូសបំព្រួញខាងក្រោម៖

គំនូសបង្ហាញទីតាំង

ថ្ងៃទី.....ខែ..... ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

និមិត្តសញ្ញារដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ .....

លេខ៖.....

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតអនុញ្ញាត
ប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម



អនុញ្ញាតឱ្យ លោក-លោកស្រី : **ម៉ុង ករុណា** **តេទ ស្រី** **ឆ្នាំកំណើត ១៩៩៣**

ប្រភេទអាជីវកម្ម-សេវាកម្ម-ពាណិជ្ជកម្ម : **ដេប៉ូប្រេងឥន្ធនៈ**

អាសយដ្ឋានអាជីវកម្ម : **ភូមិបាកយណ៍លិច សង្កាត់បាកយណ៍ ក្រុងព្រៃវែង ខេត្តព្រៃវែង**

ឈ្មោះអាជីវកម្ម : **ម៉ុង ករុណា**

ឈ្មោះអាជីវកម្មជាអក្សរឡាតាំង : MONG KAKRONA

លិខិតអនុញ្ញាតនេះមានសុពលភាពត្រឹម : **ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៦**

មុនផុតសុពលភាពប្រើប្រាស់រយៈពេល ៣០ថ្ងៃ សាមីខ្លួនត្រូវដាក់ពាក្យសុំបន្តសាជាថ្មីឡើងវិញ។

ថ្ងៃ.....ខែ.....ឆ្នាំ..... ព.ស.២៥.....

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....

អភិបាលក្រុង/ស្រុក/ខណ្ឌ.....

<u>បញ្ជាក់</u>: - លិខិតអនុញ្ញាតនេះត្រូវដាក់តាំងបង្ហាញ ឬព្យួរនៅទីកន្លែងទទួលភ្ញៀវ
- ឈ្មោះអាជីវកម្មនេះមិនត្រូវបានការពារ
- ហាមជួញដូរនិងប្រើប្រាស់គ្រឿងញៀន ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចពលកម្មកុមារ។

ONE WINDOW SERVICE OFFICE

ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត ៤ x ៦

ពាក្យស្នើសុំ
លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....(អក្សរឡាតាំង).....ភេទ.....
ថ្ងៃ-ខែ-ឆ្នាំកំណើត.....សញ្ជាតិ.....អាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....
ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....
ទូរសព្ទលេខ.....។

សូមគោរពជូន
លោក/លោកស្រីអភិបាល.....

កម្មវត្ថុ ៖ សំណើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន លោក/លោកស្រីអភិបាល មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....
រាជធានី/ខេត្ត.....។

នាមករណ៍ក្រុមហ៊ុន/សហគ្រាស/ឈ្មោះអាជីវកម្ម.....
(ជាអក្សរឡាតាំង) .....។

សូមជូនភ្ជាប់ជាមួយនូវ៖

១- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស (ច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬមានផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន) "ចំពោះរូបវន្តបុគ្គល"..ចំនួន ០១ច្បាប់
២- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ច្បាប់ថតចម្លង (ច្បាប់ថតចម្លងដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) "ចំពោះនីតិបុគ្គល".....ចំនួន ០១ច្បាប់
៣- គំរូវិក្កយបត្រអាជីវកម្មរបស់ខ្លួន (ច្បាប់ថតចម្លង) .....ចំនួន ០១សន្លឹក
៤- រូបថតម្ចាស់អាជីវកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦ .....ចំនួន ០៣សន្លឹក
៥- កិច្ចសន្យា .....ចំនួន ០១ច្បាប់
៦- គំនូសបង្ហាញទីតាំងអាជីវកម្ម .....ចំនួន ០១ច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី អភិបាល មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ៖..... (ជាអក្សរឡាតាំង) .....ភេទ.....
ថ្ងៃ-ខែ-ឆ្នាំកំណើត ៖.....សញ្ជាតិ.....
ទីកន្លែងកំណើត ៖.....
អាសយដ្ឋានបច្ចុប្បន្ន ៖.....
នាមករណ៍/ឈ្មោះអាជីវកម្ម ៖.....
ទូរស័ព្ទលេខ ៖.....
តំណាងក្រុមហ៊ុន សហគ្រាស(ករណីនីតិបុគ្គល)៖.....
(ជាអក្សរឡាតាំង) .....។

សូមសន្យាថា៖

១- មានលិខិតអនុញ្ញាត មុននឹងចាប់ផ្តើមប្រកបអាជីវកម្ម
២- រាល់ការលក់ ត្រូវមានវិក្កយបត្រត្រឹមត្រូវ និងមានសរសេរបញ្ជាក់ពីការធានាអំពីគុណភាពទំនិញឱ្យបានច្បាស់លាស់នៅលើវិក្កយបត្រ
៣- មិនក្លែងបន្លំគុណភាព រំលោភសេចក្តីទុកចិត្តអតិថិជន
៤- បិទស្លាកថ្លៃជាប្រាក់រៀលលើគ្រប់មុខទំនិញ និងសេវាដែលតាំងលក់
៥- ជូនដំណឹងមករដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានមុន៣០ថ្ងៃ ករណីឈប់ដំណើរការអាជីវកម្មមុនកាលកំណត់
៦- គោរពអនុវត្តតាមគោលការណ៍ច្បាប់ បទបញ្ជា ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ ដោយធានាមិនធ្វើអ្វី ឱ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ វប្បធម៌ និងប្រពៃណីជាតិ
៧- សហការផ្តល់ព័ត៌មានអំពីស្ថានភាពអាជីវកម្មជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ/មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត។

ក្នុងករណីខ្ញុំបាទ/នាងខ្ញុំមិនបានគោរព និងអនុវត្តតាមខ្លឹមសារដែលបានចែងខាងលើទេនោះ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំនូសបង្ហាញទីតាំង
ប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ

របស់ឈ្មោះ.....ឈ្មោះអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ.....អាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ..... រាជធានី/ខេត្ត .....ដូចបានបង្ហាញនៅក្នុងគំនូសបំព្រួញខាងក្រោម៖

គំនូសបង្ហាញទីតាំង

ថ្ងៃទី.....ខែ..... ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

និមិត្តសញ្ញារដ្ឋបាលក្រុង ស្រុក ខណ្ឌ

រដ្ឋបាលក្រុង ស្រុក ខណ្ឌ.....

លេខ:.....

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លិខិតអនុញ្ញាត

ប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ



អនុញ្ញាតឱ្យ លោក-លោកស្រី : **ម៉ុង ករុណា** **ភេទ ស្រី** **ឆ្នាំកំណើត ១៩៨០**

ប្រភេទអាជីវកម្ម : **លក់គ្រឿងអលង្ការគ្រប់ប្រភេទ**

អាសយដ្ឋានអាជីវកម្ម : **ផ្លូវត្រាំឆាត ភូមិចុងកៅស៊ូ សង្កាត់ស្ពឺក្រាម ក្រុងសៀមរាប**

ឈ្មោះ ក្រុមហ៊ុន សហគ្រាស/អាជីវកម្ម : **ម៉ុង ករុណា**

ឈ្មោះ ក្រុមហ៊ុន សហគ្រាស/អាជីវកម្មជាអក្សរឡាតាំង : MONG KAKRONA

លិខិតអនុញ្ញាតនេះមានសុពលភាពត្រឹម : **ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៧**

មុនផុតសុពលភាពប្រើប្រាស់រយៈពេល ៣០ថ្ងៃ សាមីខ្លួនត្រូវដាក់ពាក្យសុំបន្តសាជាថ្មីឡើងវិញ។

ថ្ងៃ.....ខែ.....ឆ្នាំ..... ព.ស.២៥.....

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....

អភិបាលក្រុង/ស្រុក/ខណ្ឌ.....

<u>បញ្ជាក់:</u> - លិខិតអនុញ្ញាតនេះត្រូវដាក់តាំងបង្ហាញ ឬព្យួរនៅទីកន្លែងទទួលភ្ញៀវ

- ឈ្មោះអាជីវកម្មនេះមិនត្រូវបានការពារ
- ហាមជួញដូរនិងប្រើប្រាស់គ្រឿងញៀន ការជួញដូរផ្លូវភេទ និងការកេងប្រវ័ញ្ចពលកម្មកុមារ។

ONE WINDOW SERVICE OFFICE

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត ៤x៦

ពាក្យស្នើសុំបន្ត
លិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.....(អក្សរឡាតាំង).....ភេទ.....
ថ្ងៃ-ខែ-ឆ្នាំកំណើត.....សញ្ជាតិ.....អាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....
ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....
ទូរសព្ទលេខ.....។

សូមគោរពជូន
លោក/លោកស្រីអភិបាល.....

កម្មវត្ថុ ៖ សំណើសុំបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន លោក/លោកស្រីអភិបាល មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងស្នើសុំបន្តលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ ដែលមានអាសយដ្ឋានបច្ចុប្បន្នផ្ទះ/អគារលេខ.....ផ្លូវ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....រាជធានី/ខេត្ត.....។
នាមករណ៍ក្រុមហ៊ុន/សហគ្រាស/ឈ្មោះអាជីវកម្ម.....
(ជាអក្សរឡាតាំង) .....។

សូមជូនភ្ជាប់ជាមួយនូវ៖

១- លិខិតអនុញ្ញាតប្រកបអាជីវកម្មត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទដែលជិតអស់សុពលភាព (ច្បាប់ថតចម្លង) .....ចំនួន ០១ច្បាប់
២- រូបថតម្ចាស់អាជីវកម្ម ពាណិជ្ជកម្ម (ថតចំពីមុខ) ទំហំ ៤ x ៦.....ចំនួន ០៣សន្លឹក
៣- កិច្ចសន្យា .....ចំនួន០១ច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក/លោកស្រី អភិបាល មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កិច្ចសន្យា

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ៖..... (ជាអក្សរឡាតាំង) .....ភេទ.....
ថ្ងៃ-ខែ-ឆ្នាំកំណើត ៖.....សញ្ជាតិ.....
ទីកន្លែងកំណើត ៖.....
អាសយដ្ឋានបច្ចុប្បន្ន ៖.....
នាមករណ៍/ឈ្មោះអាជីវកម្ម ៖.....
ទូរសព្ទលេខ ៖.....
តំណាងក្រុមហ៊ុន សហគ្រាស(ករណីនីតិបុគ្គល)៖.....
(ជាអក្សរឡាតាំង) .....។

សូមសន្យាថា៖

១- មានលិខិតអនុញ្ញាត មុននឹងចាប់ផ្តើមប្រកបអាជីវកម្ម
២- រាល់ការលក់ ត្រូវមានវិក្កយបត្រត្រឹមត្រូវ និងមានសរសេរបញ្ជាក់ពីការធានាអំពីគុណភាពទំនិញឱ្យបានច្បាស់លាស់នៅលើវិក្កយបត្រ
៣- មិនក្លែងបន្លំគុណភាព រំលោភសេចក្តីទុកចិត្តអតិថិជន
៤- បិទស្លាកថ្លៃលើគ្រប់មុខទំនិញដែលតាំងលក់
៥- ជូនដំណឹងមករដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានមុន៣០ថ្ងៃ ករណីឈប់ដំណើរការអាជីវកម្មមុនកាលកំណត់
៦- គោរពអនុវត្តតាមគោលការណ៍ច្បាប់ បទបញ្ជា ប្រកាស សេចក្តីសម្រេច សេចក្តីណែនាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗ ដោយធានាមិនធ្វើអ្វីឱ្យប៉ះពាលដល់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ វប្បធម៌ និងប្រពៃណីជាតិ
៧- ផ្តល់របាយការណ៍អំពីស្ថានភាពអាជីវកម្មជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ/មន្ទីរពាណិជ្ជកម្មរាជធានី ខេត្តតាមការចាំបាច់។

ក្នុងករណីខ្ញុំបាទ/នាងខ្ញុំមិនបានគោរព និងអនុវត្តតាមខ្លឹមសារដែលបានចែងខាងលើទេនោះ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន។

.....ថ្ងៃទី.....ខែ.....ឆ្នាំ២០.....
ហត្ថលេខា ឬស្នាមមេដៃអ្នកស្នើសុំ